**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ១២៩ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការបង្កើតនាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៨ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែល ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ស ម្រេ ច**

**មាត្រា១ :**

ត្រូវបានបង្កើតនាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល ចំណុះសេនាធិការដ្ឋាន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ។

ការបង្កើតនាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល ស្ថិតក្នុងគោលបំណងធ្វើកំណែទម្រង់ និងអភិវឌ្ឍប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ឱ្យស្របតាមស្ថានភាពរបស់ប្រទេសជាតិនាដំណាក់កាលបច្ចុប្បន្ន ។

**មាត្រា២ :**

នាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល មានភារកិច្ចដូចខាងក្រោម :

១- ធ្វើសេនាធិការជូនអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃក្នុងការកសាងផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពលើការងារណែនាំ តាមដានត្រួតពិនិត្យកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ សំដៅរួមចំណែកបង្ការទប់ស្កាត់ បង្ក្រាបបទល្មើស រក្សាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ។

២- តាមដានអំពីសភាពការណ៍ និងការវិវត្តន៍របស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ទូទាំងប្រទេសតាមដំណាក់កាលនីមួយៗ រាយការណ៍ និងលើកសំណូមពរជូនថ្នាក់ដឹកនាំ ដើម្បីមានគោលការណ៍ វិធានការ ផែនការចំពោះមុខ និងយូរអង្វែងលើកិច្ចការអភិវឌ្ឍប៉ុស្តិ៍នគរបាលរដ្ឋបាល ។

៣-លើកគម្រោងផែនការបណ្តុះបណ្តាល បំពាក់បំប៉ននគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់អំពីតួនាទីភារកិច្ច របៀបរបបការងារ ការងារសហគមន៍ ការគ្រប់គ្រងរដ្ឋបាល និងជំនាញផ្សេងៗទៀត ដើម្បីលើកកម្ពស់សមត្ថភាពក្នុងកិច្ចការពារសន្តិសុខសណ្តាប់ធ្នាប់នៅមូលដ្ឋាន ។

៤- ទំនាក់ទំនង សហការជាមួយអង្គការក្រៅរដ្ឋាភិបាល អង្គការជាតិ អន្តរជាតិ ដើម្បីស្វែងរកជំនួយសម្រាប់អភិវឌ្ឍប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់តាមការណែនាំរបស់ក្រសួងមហាផ្ទៃ ។

៥- ទំនាក់ទំនងសហការជិតស្និទ្ធជាមួយសមត្ថកិច្ចនានា ដើម្បីផ្តល់ពត៌មាន និងសង្គ្រោះរាល់ហានិភ័យដែលអាចកើតឡើង ។

៦- ចុះធ្វើអង្កេតដោយផ្ទាល់ដល់ទីតាំងប៉ុស្តិ៍ និងដំណើរការបូកសរុប ដកពិសោធន៍ កែលម្អកិច្ចការអភិវឌ្ឍប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់តាមដំណាក់កាលនីមួយៗ ។

៧-លើកគម្រោងសាងសង់ ជួសជុលទីស្នាក់ការប៉ុស្តិ៍ និងការបំពាក់ឧបករណ៍សម្ភារៈ និងមធ្យោបាយសម្រាប់បម្រើឱ្យការងារជំនាញប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ដាក់ស្នើជូនថ្នាក់ដឹកនាំពិនិត្យសម្រេច ។

៨-ធ្វើរបាយការណ៍ជាប្រចាំតាមការកំណត់ ឬជាបន្ទាន់អំពីសភាពការណ៍ ហេតុការណ៍ផ្សេងៗដល់ការអនុវត្តភារកិច្ចជូនអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃ ។

៩- ធ្វើការងាររដ្ឋបាល ការងារបុគ្គលិក ភស្តុភារ គណនេយ្យរបស់នាយកដ្ឋានតាមការកំណត់ ។

១០- បំពេញភារកិច្ចផ្សេងៗទៀត ដែលអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

**មាត្រា៣ :**

នាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា៤ :**

នាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល មានការិយាល័យមួយចំនួនចំណុះ ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះនាយកដ្ឋានកិច្ចការប៉ុស្តិ៍នគរបាលរដ្ឋបាល ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៥ :**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៦ :**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ ២០១២*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*កន្លែងទទួល :*

*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចមាត្រា ៦*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*